មហាអយ្យការ ប្រចាំ
សាលាឧទ្ធរណ៍ ភ្នំពេញ
លេខ ៤៧១-៩៧

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## អគ្គរដ្ឋអាជ្ញា ប្រចាំសាលាឧទ្ធរណ៍ ភ្នំពេញ

**ជម្រាបមក**

**លោកព្រះរាជអាជ្ញាប្រចាំតុលាការខេត្ត-ក្រុង**

**និងលោកចៅក្រមស៊ើបអង្កេត**

**កម្មវត្ថុ:** លិខិតឯកសារផ្សេងៗ នៅក្នុងសំណុំរឿងព្រហ្មទណ្ឌ ។

ខ្ញុំបានសង្កេតឃើញកន្លងមកតាមរយៈសំណុំរឿងផ្សេងៗមានឯកសារជាភស្តុតាងខ្លះ ដែលបញ្ជូនមកពីនគរបាលយុត្តិធម៌ ឬផ្តល់ឱ្យដោយដើមបណ្តឹងរដ្ឋប្បវេណី ដោយសាក្សី ឬដោយជនត្រូវចោទដើម្បីយកមកដាក់ក្នុងសំណុំរឿងបានត្រូវចាត់ពីសំណុំរឿង ដោយហេតុជួនកាលមកពីការច្រឡំចូលទៅក្នុងសំណុំរឿងដទៃផ្សេងទៀត ជួនកាលបណ្តាលមកពីការបំបាត់ត្រង់ៗតែម្តង អំពើចុងក្រោយនេះជាអំពើប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ បញ្ញត្តិមាត្រា ៤៦នៃច្បាប់ព្រហ្មទណ្ឌ ថ្ងៃ ១០កញ្ញា ១៩៩២ ដែលអ្នកប្រព្រឹត្តត្រូវទទួលខុសត្រូវ ។ ប៉ុន្តែការញែកកំហុសអាចប្រទះការពិបាកខ្លះដោយការទទួលបន្ទុកថែរក្សាសំណុំរឿងបានត្រូវផ្ទេរពីអស់លោកបុគ្គលិកមួយទៅមួយ ហើយការញែកនេះរឹងរឹតតែស្មុកស្មាញថែមទៀត កាលណាគ្មានការរៀបចំឱ្យទទួលខុសត្រូវតាំងពីមុនដំបូងឡើង ។

លិខិតទាំងឡាយអាចត្រូវបញ្ជូនមកតាមផ្លូវការ ជួនកាលទទួលផ្ទាល់ដៃមានចុះហត្ថលេខាទទួលត្រឹមត្រូវ (១)តាំងពីអយ្យការ ពីមន្ទីរចៅក្រមស៊ើបអង្កេត ជួនកាលទៅដំណាក់កាលចៅក្រមជំនុំជម្រះប៉ុន្តែ ទម្លាប់អនុវត្តកន្លងមកពីលោកក្រឡាបញ្ជី ចៅក្រមជំនុំជម្រះម្នាក់ប៉ុណ្ណោះជាអ្នកធ្វើបញ្ជីវាយលិខិតនៃសំណុំរឿងទាំងស្រុងតាំងពីលេខ១ ដល់លេខចុងក្រោយបញ្ចប់ ។ ទង្វើរបៀបនេះពុំមានន័យថា លោកកឡាបញ្ជីរូបនេះជាអ្នកទទួលខុសត្រូវលើលិខិតចាត់នេះទេ ព្រោះលិខិតដែលបាត់នោះអាចមានតាំងពីដំណាក់កាលនៅអយ្យការ ឬនៅមន្ទីរចៅក្រមស៊ើបសួរម្ល៉េះ ។

ដើម្បីអាចញែកកំហុសក្នុងរឿងបាត់លិខិ ឬបំបាត់លិខិតភស្តុតាងនៃសំណុំរឿងទៅថ្ងៃមុខ ខ្ញុំសូមអស់លោកព្រះរាជអាជ្ញា នឹងចៅក្រមស៊ើបអង្កេត ជួយត្រួតពិនិត្យ និងជួយចាត់ចែងរៀបចំភារៈកិច្ចរបស់អស់លោកក្រឡាបញ្ជីឱ្យធ្វើបញ្ជីវាយលិខិតតាមស្ថាប័នបន្តបន្ទាប់ គឺពីអយ្យការ ពីចៅក្រមស៊ើបរអង្កេត ដោយឡែកៗពីគ្នាដោយមានចុះលេខ និងហត្ថលេខាបំពេញ ហើយត្រូវជៀសវាងការចុះលេខ ២ដង ឬ លុបក្រវេមក្រវ៉ាមលើលេខរចុះ នៅចុងលិខិតដើម្បីជៀសវាងកង្វះសណ្តាប់ធ្នាប់ និងតម្រូវឱ្យមានការទទួលខុសត្រូវតទៅផង ។

(១)គ្រប់ឯកសារ ភស្តុតាងទទួលយកមកដាក់ក្នុងសំណុំរឿង ត្រូវតែតាក់តែងជាភាសាខ្មែរ បើឯកសារដើមរៀបរៀងជាភាសាបរទេស ត្រូវឱ្យមានការបកប្រែជាភាសាខ្មែរជាមុនហើយស្រេចសឹមទទួល ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្ងួន**

<u>ចម្លងជូន</u>

-ក្រសួងយុត្តិធម៌
-ប្រធានតុលាការខេត្ត-ក្រុង
-ដើម្បីជ្រាបជាព័ត៌មាន